## រឿងទី៨៖ ក្រុមជំនុំដើម

**ខគម្ពីរ៖ កិច្ចការ២:៤**

អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗ ពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានឲ្យ

ព្រះយេស៊ូបានសុគតដោយត្រូវឆ្កាងនៅលើឈើឆ្កាង ហើយបីថ្ងៃក្រោយទ្រង់ក៏មានព្រះជន្មរស់ឡើងវិញ។

បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ៤០ថ្ងៃក្រោយ ទ្រង់ក៏យាងទៅស្ថានសួគ៌វិញ។

ក្រោយព្រះយេស៊ូបានយាងទៅស្ថានសួគ៌ ពួកសាវកទាំងអស់បានឡើងទៅបន្ទប់ខាងលើដើម្បីអធិស្ឋានជាមួយគ្នា។

ក្រោយកន្លងបាន១០ថ្ងៃ ពិធីបុណ្យថ្ងៃទី៥០របស់ជនជាតិយូដាក៏បានមកដល់។

ដូចសព្វមួយដង ពួកសាវករបស់ព្រះយេស៊ូនិងមនុស្សផ្សេងទៀតនៅតែបន្តជួបជុំគ្នាអធិស្ឋាននៅក្នុងបន្ទប់ខាងលើ។

ប៉ុន្តែ ភ្លាមនោះស្រាប់តែមានឮសូរសន្ធឹកពីលើមេឃ ដូចខ្យល់បក់បោកយ៉ាងខ្លាំង ពេញក្នុងផ្ទះដែលគេនៅ។

ក្នុងពេលជាមួយគ្នានោះ ក៏មានអណ្ដាតភ្លើងក្រហមបែកចេញពីគ្នាចុះមកសណ្ឋិតលើពួកសាវក។

រំពេចនោះ ពួកសាវកដែលទទួលបានការជ្រមុជដោយព្រះវិញ្ញាណ ចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា ដែលសូម្បីខ្លួនគេ ក៏មិនដឹងថាជាអ្វីដែរ។

លោកពេត្រុសបានចាប់ផ្ដើមអធិប្បាយព្រះបន្ទូលទៅកាន់ហ្វូងមនុស្ស។

«ក្រោយពីព្រះយេស៊ូទ្រង់បានយាងឡើងទៅស្ថានសួគ៌វិញ ព្រះវិញ្ញាណបរិសុទ្ធក៏យាងមកជួយឱ្យមនុស្សបានយល់ដឹងពីគ្រប់ទាំងព្រះបន្ទូលដែលព្រះយេស៊ូបានបង្រៀន។

ព្រះជាម្ចាស់បានបញ្ជូនព្រះយេស៊ូឱ្យមកផែនដីនេះ ដើម្បីសង្គ្រោះអ្នករាល់គ្នា។

អស់អ្នកដែលបានស្ដាប់ការអធិប្បាយរបស់ពេត្រុសបានសួរថា៖ «បើដូច្នោះមែន តើធ្វើដូចម្ដេច ទើបអាចទទួលបានការសង្គ្រោះ?»

«ចូរជឿព្រះយេស៊ូ ហើយទទួលបុណ្យជ្រមុជទឹកនៅក្នុងព្រះនាមព្រះយេស៊ូ នោះអំពើបាបនឹងត្រូវបានអត់ទោស»។



ពេលបានឮពេត្រុសនិយាយហើយ មនុស្សទាំងអស់មានការប៉ះពាល់ចិត្តជាខ្លាំង។

នៅថ្ងៃនោះ មានមនុស្សជាងបីពាន់នាក់បានជឿតាមរយៈពេត្រុស ហើយទទួលធ្វើបុណ្យជ្រមុជទឹក។

ពួកសាវ័ករបស់ព្រះយេស៊ូ និងអ្នកដែលជឿព្រះយេស៊ូ បានមកព្រះវិហារជួបជុំគ្នា អធិស្ឋានអរព្រះគុណព្រះជាម្ចាស់រៀងរាល់ថ្ងៃ។

ហើយពួកគេទាំងនោះ បានលក់ទ្រព្យសម្បត្តិខ្លួន ចែកទានដល់អ្នកក្រខ្សត់។

ក្រោយព្រះវិញ្ញាណទ្រង់សណ្ឋិត ហើយការទាំងនេះកើតឡើង អ្នកដែលបានឃើញ គេសរសើរដល់ពួកសាវ័ក និងអ្នកដែលជឿព្រះយេស៊ូ ហើយពួកគេក៏ជឿព្រះជាម្ចាស់ និងទទួលបានការសង្គ្រោះ។

នេះគឺជាទិដ្ឋភាពរបស់ក្រុមជំនុំដំបូង



**សកម្មភាពទី១** សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ។ ផាត់ពណ៌រូបភាពព្រះវិហារខាងក្រោម រួចកាត់ធ្វើជាព្រះវិហារ។

**សម្ភារៈ៖ កន្ត្រៃ កាវ ខ្មៅដៃពណ៌**







រូបភាពរួចរាល់

**សកម្មភាពទី២** សូមឆ្លើយនិងសំណួរខាងក្រោម។

a. ពេលព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិត តើពេលនោះពួកសាវកកំពុងធ្វើអ្វី?

b. ក្រោយពីព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតហើយ តើពេត្រុសបានអធិប្បាយព្រះបន្ទូលអ្វីទៅបណ្ដាជន?

c. សូមអានព្រះគម្ពីរកិច្ចការ២:៤៣-៤៧ រួចឆ្លើយនិងសំណួរ។ តើអ្នកជឿទាំងអស់ បានមកជុំគ្នា ដើម្បីធ្វើអ្វី?

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(កិច្ចការ២:៤)

**អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ* ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានឱ្យ**